# "យុទ្ធសាស្ត្រចតុកោណ - ដំណាក់កាលទី៣"
# ( ទ្រឹស្តី និង អនុវត្ត )

បណ្ឌិត **ឆេង វណ្ណារិទ្ធ**
ប្រធានស្តីទីវិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម

សេចក្តីផ្តើម
សេចក្តីរំលឹកឡើងវិញអំពី"យុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី៣"
បញ្ហាប្រឈម
សន្និដ្ឋាន
ឯកសារយោង
ឧបសម្ព័ន្ធ

## សេចក្តីផ្តើម

ជិតពីរទសវត្សរ៍កន្លងមក រាជរដ្ឋាភិបាលបានអនុវត្តនូវយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី១សម្រាប់នីតិកាលទី៣នៃរដ្ឋសភា, យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី២សម្រាប់នីតិកាលទី៤នៃរដ្ឋសភា និង យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣សម្រាប់នីតិកាលទី៥នៃរដ្ឋសភា ប្រកបដោយជោគជ័យដើម្បី **កំណើន, ការងារ, សមធម៌** និង**ប្រសិទ្ធភាព** គួរជាទីមោទនៈបំផុត។ សមិទ្ធិផលនៃកិច្ចអភិវឌ្ឍទាំងអស់នោះ គឺជាសក្ខីភាពនៃការឈានឡើងរបស់កម្ពុជាឆ្ពោះទៅរកសន្តិភាពយូរអង្វែងនិងការអភិវឌ្ឍប្រកបដោយចីរភាពជាពិសេសជោគជ័យក្នុងការកាត់បន្ថយភាពក្រីក្រនិងការលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋទូទៅ។

ទន្ទឹមនឹងលទ្ធផលត្រចះត្រចង់ទទួលបាន កម្ពុជានៅមានបញ្ហាសេសសល់មួយចំនួនដូចជា អត្រាភាពក្រីក្រនៅតំបន់ជនបទមានកម្រិតខ្ពស់ ហើយសមិទ្ធផលក្នុងការកាត់បន្ថយគម្លាតអ្នកមាននិងអ្នកក្រ អ្នកទីក្រុងនិងអ្នកជនបទ ដែលសម្រេចបានកន្លងមក ក៏នៅមានភាពផុយស្រួយ ជាពិសេសទាក់ទងវិស័យកសិកម្មដែលមិនទាន់ដោះស្រាយបានជាស្ថាពរនៅឡើយ។

នៅក្នុងប្រធានបទនេះនឹងលើកយកខ្លឹមសារមួយចំនួននៅក្នុង **"យុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី៣" របស់រាជរដ្ឋាភិបាលនីតិកាលទី៥ នៃរដ្ឋសភា** បង្ហាញអំពីស្ថានភាពជីវភាពកសិករ និងបញ្ហាមួយចំនួននៃវិស័យកសិកម្ម ដែលនៅមិនទាន់បានដោះស្រាយ ពោលបញ្ហាដែល **"យុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី៣"** មិនទាន់សម្រេចបានតាមគោលបំណងនៅក្នុងនីតិកាលទី៥នៃរដ្ឋសភា ដើម្បីជាជំនួយស្មារតី។

## សេចក្តីរំលឹកឡើងវិញអំពី "យុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី៣"

រាជរដ្ឋាភិបាលនីតិកាលទី៥នៃរដ្ឋសភាបានកំណត់ **"យុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី៣"** ជាមគ្គុទេសក៍ច្បាស់លាស់សម្រាប់តម្រែតម្រង់សកម្មភាពរបស់គ្រប់តួអង្គអភិវឌ្ឍន៍ទាំងអស់ ក្នុងគោលដៅបន្ត និងពង្រឹងកិច្ចអភិវឌ្ឍប្រកបដោយចីរភាពសម្រាប់រយៈពេលវែង សំដៅជំរុញកំណើនសេដ្ឋកិច្ចប្រកបដោយសមធម៌ និងធានាឱ្យបាននូវប្រសិទ្ធភាពនៃស្ថាប័នសាធារណៈ និងការគ្រប់គ្រងធនធានគ្រប់ប្រភេទ។ ក្នុងខ្លឹមសារនេះ **"យុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី៣"** គឺជា **"របៀបវារៈគោលនយោបាយសង្គម-សេដ្ឋកិច្ច"** នៃកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលនីតិកាលទី៥នៃរដ្ឋសភា។

ភាពចាំបាច់ក្នុងការបន្តអនុវត្តយុទ្ធសាស្ត្រចតុកោណ គឺដោយសារតែចក្ខុវិស័យរយៈពេលវែងរបស់រាជរដ្ឋាភិបាល ដើម្បីកសាងសង្គមកម្ពុជាមួយដែលមានសន្តិភាព, ស្ថិរភាពនយោបាយ, សន្តិសុខ, សណ្តាប់ធ្នាប់សង្គម, កំណើនសេដ្ឋកិច្ចរយៈពេលវែង, ការអភិវឌ្ឍប្រកបដោយចីរភាព និង សមធម៌, ការកែលម្អជីវភាព និងការកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន, ការការពារបរិស្ថាន, ការលើកស្ទួយវប្បធម៌ និង អត្តសញ្ញាណជាតិជាមួយនឹងការគោរពយ៉ាងខ្ជាប់ខ្ជួននូវគោលការណ៍ប្រជាធិបតេយ្យសេរីពហុបក្ស ព្រមទាំងការគោរពសិទ្ធិ និងសេចក្តីថ្លៃថ្នូររបស់មនុស្ស និងមានកោសិកាផ្សារភ្ជាប់គ្នា, មានប្រជាជនប្រកបដោយចំណេះដឹងខ្ពស់ និងវប្បធម៌ជ្រៅជ្រះ, មានជីវភាពសមរម្យ និងមានការរស់នៅប្រកបដោយសុខដុមរមនាទាំងក្នុងសង្គមជាតិ ទាំងក្នុងក្រុមគ្រួសារ ព្រមទាំងមានកិត្យានុភាពខ្ពស់លើឆាកអន្តរជាតិ ក្នុងឋានៈជាសមាជិកពេញសិទ្ធិ និងស្មើសិទ្ធិនៅក្នុងសហគមន៍អន្តរជាតិ។ ស្របតាមចក្ខុវិស័យនេះ យុទ្ធសាស្ត្រចតុកោណបានដាក់ចេញនូវទិសដៅចម្បងបួនដែលស្តែងឡើងតាមរយៈបាវចនា: **កំណើន**, **ការងារ**, **សមធម៌** និង**ប្រសិទ្ធភាព**។

**"យុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី៣"** គឺជា ឧបករណ៍គោលនយោបាយប្រកបដោយប្រសិទ្ធភាពមួយក្នុងការឈានទៅសម្រេចនូវចក្ខុវិស័យខាងលើ។ លើមូលដ្ឋាននេះ រាជរដ្ឋាភិបាលបានកំណត់ ***"គោលដៅយុទ្ធសាស្ត្រ ៤"*** និង ***"វិស័យអាទិភាព ៤"*** ដើម្បីឆ្លុះបញ្ចាំងពីការប្តេជ្ញាចិត្តក្នុងការអនុវត្ត"**យុទ្ធសាស្ត្រចតុកោណ** "[1]។

- ***"គោលដៅយុទ្ធសាស្ត្រ ៤ "*** រួមមាន៖

ទី១- ធានាឱ្យបាននូវកំណើនសេដ្ឋកិច្ចក្នុងអត្រាមធ្យមប្រចាំឆ្នាំប្រមាណ៧%ប្រកបដោយចីរភាព, បរិយាប័ន្ន, សមធម៌ និងធន់នឹងវិបត្តិតាមរយៈការធ្វើពិពិធកម្មនៃមូលដ្ឋានសេដ្ឋកិច្ចឱ្យបានទូលាយ និងមានសមត្ថភាពប្រកួតប្រជែងជាងមុនក្នុងបរិការណ៍អតិផរណាមានកម្រិតទាបអាចគ្រប់គ្រងបាន, អត្រាប្តូរប្រាក់មានស្ថិរភាពនិងទុនបម្រុងមានកំណើនជាប្រចាំ។

ទី២- បង្កើតការងារឱ្យកាន់តែច្រើនឡើងជូនដល់ប្រជាជន ពិសេសសម្រាប់ស្រទាប់យុវជន តាមរយៈការបន្តខិតខំកែលម្អ និង បង្កើនភាពប្រកួតប្រជែងរបស់កម្ពុជា ក្នុងការទាក់ទាញនិងការជំរុញលើកទឹកចិត្តដល់សកម្មភាពវិនិយោគទាំងវិនិយោគក្នុងប្រទេស ទាំងវិនិយោគមកពីក្រៅប្រទេស។

ទី៣- សម្រេចឱ្យបាននូវគោលដៅនៃការកាត់បន្ថយភាពក្រីក្រក្នុងអត្រាជាង១%ក្នុងមួយឆ្នាំ ក៏ដូចជាគោលដៅផ្សេងៗទៀត ដែលត្រូវបានកំណត់ក្នុង "គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា" ទន្ទឹមនឹងការផ្តោតអាទិភាពកាន់តែខ្លាំងឡើងលើការអភិវឌ្ឍធនធានមនុស្ស, ការគ្រប់គ្រងបរិស្ថាន និងការប្រើប្រាស់ធនធានធម្មជាតិប្រកបដោយចីរភាព។

ទី៤- បន្តពង្រឹងសមត្ថភាពនិងអភិបាលកិច្ចនៃស្ថាប័នរដ្ឋទាំងថ្នាក់ជាតិ ទាំងថ្នាក់ក្រោមជាតិដើម្បីធានាឱ្យបាននូវប្រសិទ្ធភាពនិងស័ក្តិសិទ្ធិភាពនៃសេវាសាធារណៈសំដៅបម្រើប្រជាជនឱ្យកាន់តែប្រសើរឡើង។

- ***"វិស័យអាទិភាព ៤ "*** រួមមាន៖

ទី១-ការអភិវឌ្ឍធនធានមនុស្សដែលនឹងធានាបាននូវការប្រកួតប្រជែងក្នុងទីផ្សារក្នុងតំបន់ដែលកាន់តែបើកចំហរតាមរយៈ(១).ការបណ្តុះបណ្តាលពលករឱ្យមានជំនាញ និងផលិតភាពខ្ពស់តាមសេចក្តីត្រូវការនៃទីផ្សារនិងអាចបង្កើនតម្លៃបន្ថែមខ្ពស់, (២).ការរៀបចំក្របខណ្ឌគតិយុត្តនិងកសាងស្ថាប័នអប់រំនិងបណ្តុះ

[1] សូមមើល : "យុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី៣" របស់រាជរដ្ឋាភិបាលនីតិកាលទី៥នៃរដ្ឋសភា។

បណ្តាលវិជ្ជាជីវៈដែលឆ្លើយតបនឹងចំណុចទី១ខាងលើ, (៣).ការលើកទឹកចិត្តវិស័យឯកជនឱ្យចូលរួមក្នុងកិច្ចការនេះ និង(៤).ការពង្រឹងគុណភាពនៃការអប់រំ និង ការលើកកម្ពស់ការស្រាវជ្រាវវិទ្យាសាស្ត្រ និងនវានុវត្តន៍។

ទី២-ការបន្តវិនិយោគលើវិស័យហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍ និងការកែលម្អថែមទៀតនូវកិច្ចសម្រួលពាណិជ្ជកម្ម ដើម្បីកសាងប្រព័ន្ធឡូជីស្ទីកដ៏រស់រវើកតាមរយៈការសាងសង់បណ្តាញដឹកជញ្ជូនពហុសណ្ឋានក្នុងគោលដៅជានាឱ្យបាននូវការតភ្ជាប់ផ្ទៃក្នុងប្រទេស និងការតភ្ជាប់ជាមួយប្រទេសក្នុងតំបន់ និងពិភពលោក ព្រមទាំងឆ្លើយតបបានទៅនឹងការរីកចម្រើនផ្នែកនគរូបនីយកម្មដែលនឹងនាំមកនូវ(១).ការកាត់បន្ថយថ្លៃដឹកជញ្ជូន, (២).ការបង្កើនភាពអាចទុកចិត្តបាននិងភាពស័ក្តិសិទ្ធិ,(៣).ការពង្រឹងភាពប្រកួតប្រជែង និង(៤). ការបង្កើនការវិនិយោគនិងពាណិជ្ជកម្ម។ ម្យ៉ាងវិញទៀត រាជរដ្ឋាភិបាលបានបន្តផ្តល់អាទិភាពក្នុងការពង្រីកសមត្ថភាពផលិតនិងផ្គត់ផ្គង់ថាមពលពីប្រភពដែលមានតម្លៃកាន់តែទាប និងពង្រីកបណ្តាញចែកចាយសំដៅជានាសន្តិសុខថាមពល, ភាពអាចទុកចិត្តបានក្នុងការផ្គត់ផ្គង់ថាមពលព្រមទាំងថ្លៃសមរម្យដើម្បីឆ្លើយតបទៅនឹងសេចក្តីត្រូវការនៃការអភិវឌ្ឍ។

ទី៣-ការបន្តអភិវឌ្ឍ និងបង្កើនតម្លៃបន្ថែមនៃវិស័យកសិកម្មតាមរយៈ(១)ការបង្កើនតម្លៃបន្ថែមនៃការផលិតនិងការនាំចេញអង្ករ ពិសេសការផ្តោតលើអង្ករក្រអូប, អង្ករសរីរាង្គ និងកសិផលមានតម្លៃខ្ពស់ឯទៀត ដូចជា កៅស៊ូ, ស្វាយចន្ទី, ពោត, សណ្តែកសៀង, ល្ង, ម្រេច, សូត្រ, ផ្លែឈើ, កាហ្វេ, បន្លែបង្ការ, និងផ្កា ជាដើម, (២). ការជំរុញការចិញ្ចឹមសត្វ និងវារីវប្បកម្មដែលទីផ្សារត្រូវការ ដូចជា សាច់, ត្រី, ផលិតផលទឹកដោះគោ ជាដើម, (៣). ការជំរុញលើកទឹកចិត្តដល់ការវិនិយោគក្នុងវិស័យកសិ-ឧស្សាហកម្ម និង (៤). ការបង្កើនផលិតភាព, ទំនើបកម្មកសិកម្ម, និងការលើកកម្ពស់ពាណិជ្ជូបនីយកម្ម។

ទី៤-ការពង្រឹងអភិបាលកិច្ច និង សមត្ថភាពនៃស្ថាប័នរដ្ឋសំដៅបង្កើនប្រសិទ្ធភាពនៃសេវាសាធារណៈ និងកែលម្អបរិយាកាសវិនិយោគ តាមរយៈ(១). ការបន្តអនុវត្តការកែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌ ដើម្បីជានាយុត្តិធម៌សង្គម ព្រមទាំងលើកស្ទួយសិទ្ធិរបស់ប្រជាពលរដ្ឋ, សុចរិតភាព, តម្លាភាព និង គណនេយ្យភាព, (២). ការបន្តអនុវត្តការកែទម្រង់រដ្ឋបាលសាធារណៈ, ការកែទម្រង់វិមជ្ឈការនិងសហវិមជ្ឈការ ព្រមទាំងពង្រឹងស្ថាប័នត្រួតពិនិត្យដើម្បីបង្ខិតសេវាសាធារណៈឱ្យជិតប្រជាជន, លើកកម្ពស់កិច្ចដំណើរការប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ និងធានាបាននូវតុល្យភាពក្នុងការអនុវត្តអំណាច, (៣).ការបន្តអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដើម្បីជានាប្រសិទ្ធភាពក្នុងការវិភាជ និង ប្រើប្រាស់ថវិកា និង(៤). ការបង្កើនភាពទាក់ទាញចំពោះការវិនិយោគ ក្នុងនោះមានការលក់បន្ថយថ្លៃដើមនិងរបាំងធុរកិច្ច, ការពិនិត្យឡើងវិញនូវរបបលើកទឹកចិត្តដល់ការវិនិយោគ, ការពង្រឹងភាពជឿទុកចិត្ត និង ភាពអាចប៉ាន់ប្រមាណបានក្នុងការធ្វើធុរកិច្ច ព្រមទាំងផ្តោតការយកចិត្តទុកដាក់លើកិច្ចដំណើរការនៃតំបន់សេដ្ឋកិច្ចពិសេស។

សូមបញ្ជាក់ថា ក្នុងនីតិកាលកន្លងមក នៅក្នុងយុទ្ធសាស្ត្រអភិវឌ្ឍជាតិ រាជរដ្ឋាភិបាលបានកំណត់អាទិភាពចម្បង ៤ គឺ **ផ្លូវ**, **ទឹក**, **ភ្លើង** និង **មនុស្ស**។ ជាការពិត អាទិភាពទាំង៤នេះ ធ្លាប់ត្រូវបានកំណត់តាំងពីទសវត្សរ៍ឆ្នាំ១៩៨០មកម្ល៉េះ និងតទៅមុខទៀតកម្ពុជានៅតែត្រូវផ្តោតការយកចិត្តទុកដាក់លើអាទិភាពទាំង៤នេះយូរថែមទៀត ដោយគ្រាន់តែផ្លាស់ប្តូរទៅលើវិស័យជាក់លាក់ណាមួយទៅតាមកាលៈទេសៈនិងសភាពការណ៍ជាក់ស្តែងរបស់កម្ពុជាប៉ុណ្ណោះ។

ខ្លឹមសារ នៃ"**យុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី៣**" គឺ **កំណើន, ការងារ, សមធម៌** និង**ប្រសិទ្ធិភាព** ដែលជាកញ្ចប់នៃសមីការតែមួយ ដើម្បីឆ្លុះបញ្ចាំងឱ្យឃើញច្បាស់ពីការប្ដេជ្ញារបស់រាជរដ្ឋាភិបាលក្នុងការលើកស្ទួយសុខុមាលភាពរួមរបស់ប្រជាជន។

"**យុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី៣**" មានរចនាសម្ព័ន្ធ : (ក).បរិស្ថានគ្របដណ្ដប់សម្រាប់ការអនុវត្តយុទ្ធសាស្ត្រទាំងមូល, (ខ).ស្នូលនៃយុទ្ធសាស្ត្រចតុកោណ គឺអភិបាលកិច្ចល្អ, (គ).ចតុកោណយុទ្ធសាស្ត្រទាំងបួន និង(ឃ).មុំយុទ្ធសាស្ត្រនៃចតុកោណនីមួយៗ។

ក. **បរិស្ថានគ្របដណ្ដប់សម្រាប់ការអនុវត្តយុទ្ធសាស្ត្រទាំងមូល** មាន ៤ គឺៈ

- ទី១. សន្តិភាព, ស្ថិរភាពនយោបាយ, សន្តិសុខ, សណ្ដាប់ធ្នាប់សាធារណៈ
- ទី២. បរិស្ថានម៉ាក្រូសេដ្ឋកិច្ច និង ហិរញ្ញវត្ថុដែលមានលក្ខណៈអនុគ្រោះ និង ចីរភាព
- ទី៣. ភាពជាដៃគូក្នុងការអភិវឌ្ឍ
- ទី៤. សមាហរណកម្មកម្ពុជា កាន់តែស៊ីជម្រៅទៅក្នុងតំបន់ និង ពិភពលោក

ខ. **ស្នូលនៃយុទ្ធសាស្ត្រចតុកោណ គឺអភិបាលកិច្ចល្អ** មាន៤ គឺៈ

- ទី១. ការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ
- ទី២. ការកែទម្រង់ច្បាប់ និង ប្រព័ន្ធយុត្តិធម៌
- ទី៣. ការកែទម្រង់រដ្ឋបាលសាធារណៈ
- ទី៤. កំណែទម្រង់កងកម្លាំងប្រដាប់អាវុធ

គ. **ចតុកោណយុទ្ធសាស្ត្រទាំងបួន មានចតុកោណ** ៤ គឺៈ

- ទី១. ចតុកោណទី១. ការលើកស្ទួយវិស័យកសិកម្ម
- ទី២. ចតុកោណទី ២. ការអភិវឌ្ឍវិស័យហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត
- ទី៣. ចតុកោណទី ៣. ការអភិវឌ្ឍវិស័យឯកជន និងការងារ
- ទី៤. ចតុកោណទី ៤. ការកសាងសមត្ថភាព និង ការអភិវឌ្ឍធនធានមនុស្ស

ឃ. **មុំយុទ្ធសាស្ត្រនៃចតុកោណនីមួយៗ។**

***ចតុកោណទី១. ការលើកស្ទួយវិស័យកសិកម្ម*** មានមុំ៤ គឺៈ

មុំទី ១. ការលើកកម្ពស់ផលិតភាព, ពិពិធភាវូបនីយកម្ម និង ពាណិជ្ជូបនីយកម្ម

មុំទី ២. ការលើកម្ពស់ការចិញ្ចឹមសត្វ និង វារីវប្បកម្ម

មុំទី ៣. ការកែទម្រង់ដីធ្លី, ការបោសសម្អាតមីន និង សំណល់ជាតិផ្ទុះពីសង្គ្រាម

មុំទី ៤. ការគ្រប់គ្រងធនធានធម្មជាតិប្រកបដោយចីរភាព

***ចតុកោណទី២. ការអភិវឌ្ឍវិស័យហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត*** មានមុំ៤ គឺៈ

មុំទី ១. ការអភិវឌ្ឍវិស័យហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍ និង ហេដ្ឋារចនាសម្ព័ន្ធទីក្រុង

មុំទី ២. ការគ្រប់គ្រងធនធានទឹក និងប្រព័ន្ធធារាសាស្ត្រ

មុំទី ៣. ការអភិវឌ្ឍវិស័យថាមពលអគ្គិសនី

មុំទី ៤. ការអភិវឌ្ឍបច្ចេកវិទ្យាព័ត៌មាន និង គមនាគមន៍

***ចតុកោណទី ៣. ការអភិវឌ្ឍវិស័យឯកជន និងការងារ*** មានមុំ៤ គឺៈ

មុំទី ១. ការពង្រឹងវិស័យឯកជន និង ការជំរុញការវិនិយោគ និង ធុរកិច្ច

មុំទី ២. ការអភិវឌ្ឍឧស្សាហកម្ម និង សហគ្រាសធុនតូច និងមធ្យម

មុំទី ៣. ការអភិវឌ្ឍទីផ្សារការងារ

មុំទី ៤. ការអភិវឌ្ឍវិស័យធនាគារ និង ហិរញ្ញវត្ថុ

*ចតុកោណទី ៤. ការកសាងសមត្ថភាព និង ការអភិវឌ្ឍធនធានមនុស្ស* មានមុំ ៤ គឺ៖

មុំទី១. ការពង្រឹងនិងការលើកកម្ពស់វិស័យអប់រំ, វិទ្យាសាស្ត្រ, បច្ចេកវិទ្យា ព្រមទាំងការបណ្តុះបណ្តាលបច្ចេកទេស

មុំទី ២. ការលើកកម្ពស់សុខភាព និង អាហារូបត្ថម្ភ

មុំទី ៣. ការអភិវឌ្ឍប្រព័ន្ធគាំពារសង្គម

មុំទី ៤. ការជំរុញអនុវត្តគោលនយោបាយជាតិប្រជាជន និង សមភាពយេនឌ័រ។

ដោយប្រធានបទនេះ មានគោលបំណងផ្ទៀងផ្ទាត់ការអនុវត្ត **"យុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី៣"** ដែលជា **"របៀបវារៈគោលនយោបាយសង្គម-សេដ្ឋកិច្ច"** នៃកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលនីតិកាលទី៥ នៃរដ្ឋសភា" ពោលផ្ទៀងផ្ទាត់ "ទ្រឹស្តី និង អនុវត្តន៍" ទាក់ទងក្នុងវិស័យកសិកម្ម ដូច្នេះយើងលើកយកទិដ្ឋភាពទាក់ទងនឹងវិស័យនេះតែប៉ុណ្ណោះ។

## ចតុកោណទី១. ការលើកស្ទួយវិស័យកសិកម្ម

វិស័យកសិកម្ម នៅតែមានតួនាទីសំខាន់ក្នុងការទ្រទ្រង់កំណើនសេដ្ឋកិច្ច, ធានាសមធម៌, ធានាសន្តិសុខស្បៀង និងជំរុញការអភិវឌ្ឍសេដ្ឋកិច្ចជនបទ។ ចក្ខុវិស័យរបស់រាជរដ្ឋាភិបាល គឺការធ្វើទំនើបកម្មវិស័យកសិកម្ម កម្ពុជាតាមអភិក្រម និងក្នុងវិសាលភាព និង ល្បឿនថ្មី ដើម្បីប្រែក្លាយវិស័យនេះ ពីដំណាក់កាលនៃការអភិវឌ្ឍតាមបែបវិបុលកម្ម(បើកទូលាយ) ពោលគឺ ពឹងផ្អែកជាសំខាន់លើធនធានមានស្រាប់(ធនធានដី និងធនធានធម្មជាតិផ្សេងទៀត) និងពឹងផ្អែកលើការប្រើប្រាស់ធាតុចូលកសិកម្មតាមបែបប្រពៃណី ឈានទៅរកដំណាក់កាលថ្មីដែលផ្តោតលើផលិតកម្មតាមបែបប្រពលកម្ម(ស៊ីជម្រៅ) ពោលគឺ ពឹងផ្អែកជាសំខាន់លើការប្រើប្រាស់បច្ចេកទេស, បច្ចេកវិទ្យាថ្មី. ការស្រាវជ្រាវ និង ការអភិវឌ្ឍ, យន្តូបនីយកម្មព្រមទាំងការបង្កើនសមត្ថភាពស្រោចស្រព ដើម្បីលើកកម្ពស់ផលិតភាព, ពិពិធកាវូបនីយកម្មមុខដំណាំ និងផលិតផលកសិកម្មផ្សេងទៀត រួមទាំងការចិញ្ចឹមសត្វ និង វារីវប្បកម្មផង ដោយគិតគូរផងដែរ អំពីភាពចាំបាច់ក្នុងការគ្រប់គ្រងដីធ្លីប្រកបដោយប្រសិទ្ធភាព និង ការធានាចីរភាពបរិស្ថាននិងធម្មជាតិ។ ទន្ទឹមនេះ ការបន្តជំរុញការធ្វើពាណិជ្ជូបនីយកម្ម និងការអភិវឌ្ឍវិស័យកសិ-ឧស្សាហកម្មនឹងជួយបង្កើនតម្លៃបន្ថែមនៃផលិតផលកសិកម្ម ក៏ដូចជាជួយបង្កើនចំណូលជូនប្រជាកសិករ។

### មុំទី ១. ការលើកកម្ពស់ផលិតភាព, ពិពិធកាវូបនីយកម្ម និង ពាណិជ្ជូបនីយកម្ម

គោលដៅយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលក្នុងនីតិកាលទី៤ គឺការលើកកម្ពស់ផលិតភាព និង ការធ្វើពិពិធកាវូបនីយកម្មកសិកម្ម តាមរយៈការពង្រីកសមត្ថភាពផលិតលើផ្ទៃដីដែលមានស្រាប់ ដោយផ្តោតលើអន្តរាគមន៍ប្រទាក់ក្រឡាក្នុងវិស័យពាក់ព័ន្ធដូចជា ការប្រើប្រាស់ធាតុចូលកសិកម្មតាមបច្ចេកទេស, ការស្រាវជ្រាវ និងការអភិវឌ្ឍ, ប្រព័ន្ធសេវាបច្ចេកទេសកសិកម្ម, ការសាងសង់និងថែទាំហេដ្ឋារចនាសម្ព័ន្ធជនបទ, ការផ្តល់ឥណទានជនបទ និងមីក្រូហិរញ្ញវត្ថុ, ការពង្រីកទីផ្សារកសិកម្ម, ការរៀបចំសហគមន៍កសិកម្ម និងការគ្រប់គ្រងដីធ្លី

កសិកម្ម។

រាជរដ្ឋាភិបាលនីតិកាលទី៥ បានខិតខំរក្សាកំណើនក្នុងវិស័យកសិកម្មនេះក្នុងរង្វង់៥%ក្នុងមួយឆ្នាំ ដោយបន្តលើកម្ពស់ផលិតភាព, ធ្វើពិពិធភាវូបនីយកម្មនិងធ្វើពាណិជ្ជូបនីយកម្ម។

លើមូលដ្ឋាននេះរាជរដ្ឋាភិបាលបានផ្តោតលើអាទិភាព៖

ទី១. ការបន្តបង្កើនផលិតភាពស្រូវ និងដំណាំផ្សេងទៀត តាមរយៈការពង្រឹង, ពង្រីក និងការធានាចីរភាពនៃប្រព័ន្ធសេវាបច្ចេកទេស និង ព័ត៌មានទីផ្សារកសិកម្ម ដោយជំរុញសេវាទាំងនេះឱ្យមានរចនាសម្ព័ន្ធទៅដល់មូលដ្ឋាន ហើយផ្សារភ្ជាប់ជាមួយនឹងបណ្តាញអ្នកស្ម័គ្រចិត្ត និង ដៃគូ ដែលមានការពាក់ព័ន្ធ, ការលើកកម្ពស់ការស្រាវជ្រាវ និងការអភិវឌ្ឍដើម្បីបង្កើនផលិតភាព និង បន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ, ការផលិត និង ការប្រើប្រាស់ពូជដែលមានគុណភាព និងឆ្លើយតបទៅនឹងសេចក្តីត្រូវការទីផ្សារ, ការបន្តវិនិយោគនិងការធ្វើវិចារណកម្មការប្រើប្រាស់ហេដ្ឋារចនាសម្ព័ន្ធស្រោចស្រព, ការបន្តកែលម្អប្រព័ន្ធប្រមូលនិងទុកដាក់កសិផល, ការរៀបចំនិងការកែសម្រួលក្របខណ្ឌគតិយុត្តសម្រាប់គ្រប់គ្រងការផលិតពូជ, ការនាំចូលធាតុចូលកសិកម្ម, ប្រព័ន្ធកសិកម្មតាមកិច្ចសន្យា, ដីកសិកម្ម, សហគមន៍កសិកម្ម និងសហគមន៍ប្រើប្រាស់ទឹក ព្រមទាំងការអភិវឌ្ឍធនធានមនុស្សសម្រាប់វិស័យកសិកម្ម។

ទី២. ការបន្តជំរុញពិពិធកម្មតាមរយៈការលើកកម្ពស់ការស្រាវជ្រាវនិងការអភិវឌ្ឍ, ការផ្សព្វផ្សាយមុខដំណាំថ្មីៗដែលមានសក្តានុពលសម្រាប់ការដាំដុះនិងការនាំចេញ, ការពង្រឹងបរិស្ថានអនុគ្រោះសម្រាប់ទាក់ទាញការវិនិយោគឯកជន ពិសេសការស្រាវជ្រាវ, ការផលិត, ការចែកចាយពូជ និង ការកែច្នៃកសិកម្ម, ការបង្កើនកិច្ចសហប្រតិបត្តិការជាមួយគ្រប់ដៃគូពាក់ព័ន្ធទាំងអស់ ក្នុងការផ្ទេរចំណេះដឹង ចំណេះធ្វើ និងបច្ចេកវិទ្យាថ្មីៗដល់កសិករ និងជំរុញការប្រើប្រាស់គ្រឿងយន្តកសិកម្ម។

ទី៣. ការបន្តលើកកម្ពស់ពាណិជ្ជូបនីយកម្ម តាមរយៈការជំរុញការអនុវត្តច្បាប់ និងគោលនយោបាយព្រមទាំងការពង្រឹងយន្តការស្ថាប័ន ដើម្បីជំរុញការធ្វើពាណិជ្ជកម្ម និងការនាំចេញកសិផល រួមមានការអនុវត្តប្រកបដោយប្រសិទ្ធភាពនូវច្បាប់ស្តីពីសហគមន៍កសិកម្ម, ការលើកកម្ពស់សមត្ថភាពកែច្នៃ, ការកែលម្អថែមទៀតនូវកិច្ចសម្រួលពាណិជ្ជកម្ម រួមបញ្ចូលនូវយន្តការ "ច្រកចេញ-ចូលតែមួយ" ផង, ការពង្រឹងប្រព័ន្ធឡូជិស្ទីក, ការលើកស្ទួយគុណភាពកសិផលឱ្យស្របតាមស្តង់ដាអន្តរជាតិ, ការបង្កើនសមត្ថភាពក្នុងការផ្តល់ហិរញ្ញប្បទានតាមថ្លៃសមរម្យ, ការលើកស្ទួយភាពជាដៃគូរវាងកសិករ និង ពាណិជ្ជករ ក៏ដូចជាការលើកស្ទួយភាពដៃគូរវាងកសិ-ឧស្សាហកម្មខ្នាតធំ និង កសិកម្មលក្ខណៈគ្រួសារ។

ទន្ទឹមនឹងអាទិភាពខាងលើនេះរដ្ឋាភិបាលបានបន្តជំរុញអនុវត្ត "គោលនយោបាយស្តីពីការជំរុញផលិតកម្មស្រូវនិងការនាំចេញអង្ករ"និង"យុទ្ធសាស្រ្តសម្រាប់ការអភិវឌ្ឍកៅស៊ូធម្មជាតិនៅកម្ពុជាឆ្នាំ២០១១-២០២០" ឱ្យបានសម្រេចជោគជ័យតាមការគ្រោងទុក។

ក្នុងការអនុវត្ត "**យុទ្ធសាស្រ្តចតុកោណ-ដំណាក់កាលទី៣**" រាជរដ្ឋាភិបាលសម្រេចបានសមិទ្ធផលធំៗដូចជា[2] ៖

-សេដ្ឋកិច្ចមានកំណើនខ្ពស់ក្នុងអត្រា៧% ក្នុងមួយឆ្នាំដែលធ្វើឱ្យកម្ពុជាសម្រេចបានឋានៈប្រទេសចំណូលមធ្យមកម្រិតទាប, មូលដ្ឋាននៃកំណើនសេដ្ឋកិច្ចកាន់តែមានពិពិធកម្មច្រើនឡើង, ភាពក្រីក្រត្រូវបានកាត់បន្ថយមកនៅក្រោម១០%, និង គម្លាតនៃចំណូលក្នុងចំណោមប្រជាជនស្ថិតក្នុងកម្រិតទាបតាមរយៈការ

[2] - ដ -ទំព័៤-៥។

បែងចែកផលនៃកំណើនសេដ្ឋកិច្ចដល់ប្រជាជនគ្រប់ស្រទាប់ ពិសេសគឺតាមរយៈការអនុវត្តគោលនយោបាយដំឡើងបៀវត្សមន្ត្រីរាជការ និងប្រាក់ឈ្នួលអប្បបរមា ព្រមទាំងការគិតគូរពីសុខុមាលភាពរបស់កម្មករ តាមរយៈការតភ្ជាប់បណ្ដាញអគ្គិសនី និង បណ្ដាញទឹកស្អាតដោយតម្លៃទាប, ការពង្រឹងវិសាលភាពបេឡាជាតិរបបសន្តិសុខសង្គម និង មូលនិធិសមធម៌, ការផ្ដល់សេវាដឹកជញ្ជូនសាធារណៈ និងការជំរុញអនុវត្តយន្តការដោះស្រាយវិវាទការងារ។

-កម្ពុជាបានក្លាយជាប្រទេសមួយ ក្នុងចំណោមប្រទេសនាំអង្ករចេញធំៗ១០ ដែលក្នុងឆ្នាំ២០១៧ បាននាំចេញអង្ករប្រមាណ៦៣៥ ពាន់តោន, កើនឡើងជិតពីរដងធៀបនឹងឆ្នាំ២០១៣។ លើសពីនេះ, កម្ពុជាបាននាំចេញផលិតផលកសិកម្មសរុប ក្នុងកំណើនពី៣,៦៦លានតោន ក្នុងឆ្នាំ២០១៣ ដល់ ៥,១៤លានតោន ក្នុងឆ្នាំ២០១៧។ ក្នុងន័យនេះ, កម្ពុជាសម្រេចបានកំណើនវិជ្ជមានក្នុងវិស័យកសិកម្ម ទោះបីវិស័យនេះទទួលរងនូវផលប៉ះពាល់ដោយសារថ្លៃកសិផលទាបលើផ្សារអន្តរជាតិ, ការបាត់បង់កម្លាំងពលកម្ម និងភាពងាយរងគ្រោះដោយបាតុភូតធម្មជាតិក្ដី។

## បញ្ហាប្រឈម

ទន្ទឹមគ្នានឹងសមិទ្ធផលនៃកិច្ចអភិវឌ្ឍធំៗគួរជាទីមោទនៈដែលរាជរដ្ឋាភិបាលនីតិកាលទី៥សម្រេចបាន ក៏នៅមានបញ្ហាមួយចំនួន ជាពិសេសទាក់ទងនឹងវិស័យកសិកម្មនៅជនបទ ដែលមិនទាន់ត្រូវបានដោះស្រាយបានប្រសើរនៅឡើយ។

ខាងក្រោមនេះគឺជាបញ្ហាប្រឈមមួយចំនួនដែលក្រុមស្រាវជ្រាវនៃវិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គមនៃរាជបណ្ឌិត្យសភាកម្ពុជាបានរកឃើញតាមរយៈការចុះស្រាវជ្រាវផ្ទាល់ដល់ទីកន្លែងនៅខេត្តប៉ៃលិនក្នុងឆ្នាំ២០១៥ ហើយដែលបានចុះផ្សាយក្នុង**ទស្សនាវដ្ដីនៃវិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គមនៃរាជបណ្ឌិត្យសភាកម្ពុជា ឆ្នាំទី០១ លេខពិសេស ចេញផ្សាយថ្ងៃទី៧ ខែមករា ឆ្នាំ២០១៩** [3] និង ក្នុង**គេហទំព័រ** ihssrac.com។

លទ្ធផលវិភាគទិន្នន័យស្ថានភាពសេដ្ឋកិច្ច និង សង្គម នៅខេត្តប៉ៃលិនគឺ៖

-ប្រជាជនប្រមាណជា៧២%ជាកសិករ ប្រាក់ចំណូលជាមធ្យមក្នុងមនុស្សម្នាក់ៗពីដំណាំស្រូវមានប្រមាណជា ៥៣ដុល្លារអាមេរិកតែប៉ុណ្ណោះក្នុងមួយឆ្នាំ

-ផលដំណាំស្រូវគ្មានតម្រូវការធ្វើឱ្យថ្លៃធ្លាក់ចុះជាលំដាប់ពីមួយឆ្នាំទៅមួយឆ្នាំ

-ចំនួនគ្រួសារគ្មានដីស្រែ-ចម្ការ និងមានដីស្រែ-ចម្ការតិចជាង១ហិកតា មានចំនួនជិត៤៣% (៦៦៨៩ គ្រួសារ ក្នុងចំណោម ១៥ ៥៦៦ គ្រួសារ)នៃប្រជាពលរដ្ឋសរុបក្នុងខេត្ត

-ប្រជាពលរដ្ឋ ចាប់ពីអាយុ១៨-៦០ឆ្នាំ មានប្រមាណជា៦០% នៃចំនួនប្រជាពលរដ្ឋសរុបក្នុងខេត្តនេះ ប៉ុន្តែគ្មានទីកន្លែងការងារគ្រប់គ្រាន់ដែលអាចផ្គត់ផ្គង់ជីវភាពរបស់ពួកគេបាន

-វិស័យឧស្សាហកម្ម ភាគច្រើនគឺជាសិប្បកម្មតូចៗលក្ខណៈគ្រួសារ ប្រើប្រាស់កម្លាំងពលកម្ម តិចតួចបំផុត មិនអាចស្រូបកម្លាំងពលកម្មតាមអត្រាកំណើនក្នុងខេត្ត។

-ចំនួនអ្នកធ្វើចំណាកស្រុកនៅក្នុងប្រទេសនិងក្រៅប្រទេសកើនឡើងជាលំដាប់ពីមួយឆ្នាំទៅមួយឆ្នាំ។

---

[3] សូមមើល : ទស្សនាវដ្ដីនៃវិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គមនៃរាជបណ្ឌិត្យសភាកម្ពុជា ឆ្នាំទី០១ លេខពិសេស ចេញផ្សាយថ្ងៃទី៧ ខែមករា ឆ្នាំ២០១៩, ទំព័រ១-៤៣។

-ចំនួនប្រជាជនដែលជំពាក់បំណុលឬខ្ចីប្រាក់ពីមីក្រូហិរញ្ញវត្ថុនិងធនាគារ បានកើនឡើងខ្លាំងក្នុងឆ្នាំ២០១៥(ចំនួនអ្នកខ្ចីលុយពីមីក្រូហិរញ្ញវត្ថុនិងធនាគារក្នុងឆ្នាំ២០១៣មានចំនួន២៨១៨នាក់, ឆ្នាំ២០១៤ ចំនួន ១៣៤៧នាក់, ក្នុងឆ្នាំ២០១៥ ឡើងដល់ ៤៣៤៦នាក់។ ផលធៀបអ្នកខ្ចីលុយក្នុងប្រជាជន១០០០នាក់ ក្នុងឆ្នាំ ២០១៣មានចំនួន៤១,៤នាក់,ឆ្នាំ២០១៤ចំនួន២០,៥នាក់,ក្នុងឆ្នាំ២០១៥ឡើងដល់៦៤,៩នាក់)[4]។

បញ្ហាប្រឈមខាងលើនេះ គឺជាសញ្ញាណដ៏គួរបារម្ភពីជីវភាពប្រជាជនខេត្តប៉ៃលិន ដែលអាចនឹងកាន់តែក្រីក្រ ហើយនឹងធ្វើចំណាកស្រុកកាន់តែច្រើនឡើងថែមទៀតទៅតាមបណ្ដាខេត្តដទៃនៅក្នុងប្រទេសនិងចាកចេញទៅក្រៅប្រទេសស្របពេលដែលខេត្តនេះនៅមានដង់ស៊ីតេទាបនៅឡើយ(៨២នាក់/គ.ម២) និងជាកត្តាប៉ះពាល់អវិជ្ជមានខ្លាំងដល់សេដ្ឋកិច្ចសង្គមជាតិទាំងមូលផងដែរ។

ដោយឡែក បញ្ហាទីផ្សារបន្លែនៅប្រទេសកម្ពុជាក៏មានស្ថានភាពមិនសូវល្អប្រសើរដូចគ្នានេះដែរ។ លទ្ធផលនៃការស្រាវជ្រាវទាក់ទងនឹង **"បញ្ហា និង ដំណោះស្រាយទីបន្លែនៅកម្ពុជា"** ដែលបានចុះផ្សាយក្នុង**ទស្សនាវដ្ដីនៃវិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គមនៃរាជបណ្ឌិត្យសភាកម្ពុជាឆ្នាំទី០១លេខ១ចេញ ផ្សាយត្រីមាសទី១(ខែមករា-មីនា)ឆ្នាំ២០១៩** និង ក្នុង**គេហទំព័រ** ihssrac.com បានសរសេរថា[5]៖ ទោះបីប្រទេសកម្ពុជាពឹងផ្អែកលើវិស័យកសិកម្មមួយចំណែកធំយ៉ាងណាក្ដី ក៏បច្ចុប្បន្ននេះ ប្រទេសនេះកំពុងជួបនឹងកង្វះខាតបន្លែសម្រាប់ផ្គត់ផ្គង់តម្រូវការក្នុងស្រុក ដែលជាហេតុឲ្យនាំចូលបន្លែពីប្រទេសជិតខាងជារៀងរាល់ថ្ងៃ។ តាមការសិក្សាស្រាវជ្រាវពីប្រភពផ្សេងៗបានបង្ហាញឱ្យឃើញថា ប្រទេសកម្ពុជានាំចូលបន្លែពីក្រៅប្រទេសមានចំនួនប្រមាណជា ២០០តោន ទៅ ៤០០តោនក្នុងមួយថ្ងៃៗ សម្រាប់ផ្គត់ផ្គង់ទីផ្សារក្នុងស្រុក ហើយបន្លែទាំងនោះភាគច្រើននាំចូលពីប្រទេសវៀតណាម ថៃ និង ចិន ដោយចំណាយថវិកាជាង២០០លានដុល្លារអាមេរិកក្នុងមួយឆ្នាំៗ។ តាមរបាយការណ៍របស់អង្គការស្បៀងអាហារ និងកសិកម្មនៃអង្គការសហប្រជាជាតិបានបង្ហាញថា «បរិមាណបន្លែដែលផ្គត់ផ្គង់នៅកម្ពុជា មានប្រមាណជិត១លានតោនក្នុង១ឆ្នាំៗ ដែលក្នុងនោះបរិមាណបន្លែផ្គត់ផ្គង់ក្នុងស្រុកមានត្រឹមតែ៤៤%ប៉ុណ្ណោះ ចំណែកការនាំចូលមានរហូតដល់៥៦% ដោយឡែកនៅរាជធានីភ្នំពេញ បន្លែចំនួន៧០ភាគរយ ជាបន្លែនាំពីប្រទេសថៃ និងវៀតណាម រីឯ បន្លែរបស់ប្រជាកសិករកម្ពុជា មានតែប្រមាណ៣០ភាគរយប៉ុណ្ណោះ។ មូលហេតុនៃការនាំចូលបន្លែយ៉ាងសន្ធឹកសន្ធាប់បែបនេះពីប្រទេសជិតខាងដោយសារតែ បន្លែនាំចូលទាំងនោះមានតម្លៃថោក ស្របពេលដែលបន្លែរបស់កសិករខ្មែរមិនគ្រប់គ្រាន់តាមតម្រូវការទីផ្សារ ឬ មានថ្លៃខ្ពស់ជាងបន្លែនាំចូល(កសិករទាមទារតម្លៃលក់បន្លែខ្ពស់ជាង ពី ២០ ទៅ ៣០ ភាគរយ។

សូមរំលឹកនិងបញ្ជាក់ផងដែរថា ចំណោមប្រជាជនប្រមាណ១៦លាននាក់(២០១៨) កម្លាំងពលកម្មសកម្មចំនួន៨,៣៥លាន(ស្រី៤,០៣លាន)(២០១៥) ក្នុងនេះអ្នកប្រកបរបរកសិកម្មចំនួន៣,៤៦លាន(៤១,៥%)(ស្រី១,៧៧លាន) ប្រកបរបរឧស្សាហកម្មចំនួន២,១៣លាន(២៥,៥%)(ស្រី០,៩៩លាន) ប្រកបរបរសេវាកម្មចំនួន២,៧៥លាន(៣២,៩%)(ស្រី១,២៥លាន)និងមានអត្រាភាពក្រីក្រនៅទូទាំងប្រទេស ១៣,៥%(២០១៤)(*សូមមើលបទអន្តរាគមន៍ស្ដីពី "សេដ្ឋកិច្ចកម្ពុជា:ស្ថានភាពនិងទស្សនវិស័យ, ដោយ វង្សី វិសុត, ថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០១៩*)។ ក្នុងចំណោមប្រជាជនក្រីក្រនៅទូទាំងប្រទេស គឺភាគច្រើនជាប្រជាជនដែលរស់នៅក្នុងតំបន់

---

[4] -ដ-, ទំព័រ ១២-១៣

[5] សូមមើល : ទស្សនាវដ្ដីនៃវិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គមនៃរាជបណ្ឌិត្យសភាកម្ពុជាឆ្នាំទី០១លេខ១ចេញ ផ្សាយត្រីមាសទី១(ខែមករា-មីនា)ឆ្នាំ២០១៩, ទំព័រ ១-១១

ជនបទដែលប្រកបរបរកសិកម្ម(៤០% ក្នុងឆ្នាំ១៩៩៤ និង៣៥%ក្នុង ឆ្នាំ២០០៧ - *សូមមើលៈ យុទ្ធសាស្ត្រជាតិគាំពារសង្គមសម្រាប់ជនក្រីក្រ និង ជនងាយរងគ្រោះ(២០១១-២០១៥),ទំព័រ២៣*)។

សរុបសេចក្តីមក កម្ពុជានៅតែបន្តជួបបញ្ហាប្រឈមមួយចំនួន ពិសេសភាពងាយរងគ្រោះនៃប្រព័ន្ធដាំដុះ, ផលិតភាព និងតម្លៃបន្ថែមនៅទាប ដែលឆ្លុះបញ្ចាំងពីសេចក្តីត្រូវការក្នុងការកែលម្អថែមទៀតនូវប្រព័ន្ធដាំដុះ រួមមាន ប្រព័ន្ធធារាសាស្ត្រ, បច្ចេកវិទ្យាដាំដុះ, ការប្រើប្រាស់ធាតុចូលតាមបច្ចេកទេស, ប្រព័ន្ធប្រមូល និងទុកដាក់កសិផល, សមត្ថភាពកែច្នៃ, ប្រព័ន្ធឡូជិស្ទីក និង ស្តង់ដាគុណភាព, អនាម័យ និងភូតគាមអនាម័យ ព្រមទាំងហិរញ្ញប្បទានជាដើម ។

ការជំរុញធ្វើពិពិធកម្ម និងលើកកម្ពស់ផលិតភាពនៃវិស័យកសិកម្ម គឺជាបញ្ហាប្រឈម ដែលត្រូវដោះស្រាយបន្ទាន់នៅក្នុងល្បឿន និងទំហំថ្មីមួយ ពីព្រោះថា វិស័យកសិកម្មនៅបន្តដើរតួនាទីសំខាន់នៅក្នុងសេដ្ឋកិច្ចជាតិ ជាពិសេសសម្រាប់កាត់បន្ថយភាពក្រីក្រ, ការកាត់បន្ថយចំណាយទ្រទ្រង់ជីវភាពរស់នៅប្រចាំថ្ងៃ និងការបង្កើតការងារជូនប្រជាជន។ លើសពីនេះ, វិស័យនេះ អាចរួមចំណែកទប់ស្កាត់ការធ្លាក់ចូលក្នុងភាពក្រីក្រសាជាថ្មី និងបង្រួមគម្លាតចំណូលរបស់ប្រជាជន ក៏ដូចជាគម្លាតរវាងទីក្រុង និង ជនបទផងដែរ។ ម៉្យាងទៀត, ការវិនិយោគលើវិស័យកសិកម្មនឹងជួយធានានូវសន្តិសុខស្បៀងក្នុងរយៈពេលវែង ព្រមទាំងអាចរក្សាថ្លៃម្ហូបអាហារឱ្យនៅទាប ដែលជួយរក្សាកម្រិតបៀវត្សពិតឱ្យបានល្អប្រសើរ។

## សន្និដ្ឋាន

រាជរដ្ឋាភិបាលនីតិកាលទី៥នៃរដ្ឋសភាបានអនុវត្តនិងសម្រេចបានលទ្ធផលធំៗជាច្រើនគួរជាទីមោទនៈ ប៉ុន្តែនៅមានបញ្ហាមួយចំនួនទាក់ទងនឹងវិស័យកសិកម្មនិងប្រជាកសិករ ដែលពុំទាន់បានដោះស្រាយ ហើយនៅតែបន្តជាបញ្ហាប្រឈម ដូចជា ភាពងាយរងគ្រោះនៃប្រព័ន្ធដាំដុះ, ផលិតភាព និងតម្លៃបន្ថែមនៅទាប ដែលឆ្លុះបញ្ចាំងពីសេចក្តីត្រូវការក្នុងការកែលម្អថែមទៀតនូវប្រព័ន្ធដាំដុះ រួមមាន ប្រព័ន្ធធារាសាស្ត្រ, បច្ចេកវិទ្យាដាំដុះ, ការប្រើប្រាស់ធាតុចូលតាមបច្ចេកទេស, ប្រព័ន្ធប្រមូល និងទុកដាក់កសិផល, សមត្ថភាពកែច្នៃ, ស្តង់ដាគុណភាពកសិផល, អនាម័យ និងភូតគាមអនាម័យ ថ្លៃនិងទីផ្សារកសិផល ព្រមទាំងហិរញ្ញប្បទាន ជាដើម ។

ចំណុចខ្លាំងនៃយុទ្ធសាស្ត្រចតុកោណគឺការផ្តល់ក្របខណ្ឌគោលនយោបាយប្រទាក់ក្រឡាគ្នា គ្រប់ជ្រុងជ្រោយ និង ប្រកបដោយសង្គតិភាពព្រមទាំងគ្របដណ្តប់លើវិស័យសំខាន់ៗ សម្រាប់ការចូលរួមគាំទ្រអនុវត្តពីគ្រប់ក្រសួង-ស្ថាប័នរបស់រាជរដ្ឋាភិបាល ដែលជាមូលដ្ឋានយ៉ាងសំខាន់សម្រាប់ការវិភាជន៍ធនធានឆ្ពោះទៅអាទិភាពគោលនយោបាយ និងជាក្របខណ្ឌមួយដ៏ល្អសម្រាប់កិច្ចសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍន៍ទាំងអស់ដែលមានការពាក់ព័ន្ធ។

ចំណុចខ្សោយនៃយុទ្ធសាស្ត្រចតុកោណគឺបញ្ហាប្រសិទ្ធភាពនៃការអនុវត្ត ដែលពាក់ព័ន្ធជាសំខាន់ទៅនឹងសមត្ថភាពស្ថាប័ននិងប្រសិទ្ធភាពនៃការសម្របសម្រួលរវាងក្រសួង-ស្ថាប័ន នៅក្នុងការដាក់ចេញ និង អនុវត្តវិធានការគោលនយោបាយជាក់ស្តែង។ ម្យ៉ាងវិញទៀត សកម្មភាពអនុវត្តប្រចាំថ្ងៃ ក៏នៅមានគម្លាត និង មិនបានផ្សារភ្ជាប់ល្អ ទៅនឹងគោលបំណង និងគោលនយោបាយរបស់រាជរដ្ឋាភិបាល និង របស់ក្រសួង-ស្ថាប័ន។

ដូច្នេះ សម្រាប់**រាជរដ្ឋាភិបាលនីតិកាលទី៦ នៃរដ្ឋសភា** មានភាពចាំបាច់នៃការបន្តអនុវត្ត **"យុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី៤"** តទៅមុខទៀត ៕

# ឯកសារយោង

១.	*វង្សី វិស្សុត "សេដ្ឋកិច្ចកម្ពុជា:ស្ថានភាពនិងទស្សនវិស័យ", ថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០១៩។*

២.	*"យុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី៣" របស់រាជរដ្ឋាភិបាលនីតិកាលទី ៥ នៃរដ្ឋសភា។*

៣.	*ទស្សនាវដ្តីនៃវិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គមនៃរាជបណ្ឌិត្យសភាកម្ពុជា ឆ្នាំទី០១ លេខពិសេស ចេញផ្សាយថ្ងៃទី៧ ខែមករា ឆ្នាំ២០១៩។*

៤.	*ទស្សនាវដ្តីនៃវិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គមនៃរាជបណ្ឌិត្យសភាកម្ពុជាឆ្នាំទី០១ លេខ១ ចេញផ្សាយត្រីមាសទី១(ខែមករា-មីនា)ឆ្នាំ២០១៩។*

# ឧបសម្ព័ន្ធ








